# <u>**សេចក្តីថ្លែងការណ៍បិទបញ្ចប់បេសកកម្ម**</u>

<u>សេចក្តីថ្លែងការណ៍ដោយអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមនុស្សនៅកម្ពុជា</u>
<u>អ្នកស្រី **សាស្ត្រាចារ្យ រ៉ូណា ស្មីត**</u>
ភ្នំពេញ ១៨ សីហា ២០១៧

**ត្រួតពិនិត្យមុនបញ្ជូនចេញ**

## ***១. សេចក្តីផ្តើម***

នៅពេលនេះ ខ្ញុំបានបញ្ចប់ដំណើរបេសកកម្មលើកទី៤ របស់ខ្ញុំ នៅព្រះរាជាណាចក្រកម្ពុជាហើយ។ ខ្ញុំសូមថ្លែងអំណរគុណដល់រដ្ឋាភិបាលចំពោះការអញ្ជើញខ្ញុំឲ្យមកធ្វើទស្សនកិច្ច និងឆន្ទៈរបស់រដ្ឋមន្ត្រីជាច្រើនរូប ដើម្បីជួបប្រជុំជាមួយខ្ញុំ និងពិភាក្សាដោយចំហរអំពីវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការអនុវត្តសិទ្ធិមនុស្សនៅកម្ពុជា។ ខ្ញុំសូមសំដែងការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់បុគ្គលិកការិយាល័យOHCHR ទាំងអស់នៅកម្ពុជា ទាំងនៅរាជធានីភ្នំពេញ និងនៅខេត្តបាត់ដំបង ដែលបានគាំទ្រប្រកបដោយសមត្ថភាពបំផុតដល់ដំណើរបេសកកម្មរបស់ខ្ញុំ។

នៅក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចនេះ ខ្ញុំមានឱកាសជួបប្រជុំជាមួយមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋា-ភិបាល រួមមាន សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម **អង្គ វង្សវឌ្ឍានា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឯកឧត្តម **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវ-នីតិសម្បទា ឯកឧត្តម **អ៊ុច បូរិទ្ធ** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តម **កែវ រ៉េមី** ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ឯកឧត្តម **ស៊ិក ប៊ុនហុក** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រមទាំង ឯកឧត្តម **ស៊ុយ អារ៉ាផាត** អភិបាលរងខេត្តបាត់ដំបង និង ឯកឧត្តម **អ៊ុំ រាត្រី** អភិបាលរងខេត្តបន្ទាយមានជ័យ។ ខ្ញុំក៏បានជួបផងដែរ ជាមួយមេដឹកនាំគណបក្សសង្គ្រោះជាតិកម្ពុជា ឯកឧត្តម **កឹម សុខា**។

ក្រៅពីជំនួបប្រជុំទាំងនោះ នៅរាជធានីភ្នំពេញ ខ្ញុំបានធ្វើទស្សនកិច្ចទៅកាន់ខេត្តបាត់ដំបង និងទៅកាន់ស្រុកសេរីសោភ័ណ និងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ទាំងនៅរាជធានីភ្នំពេញ ទាំងនៅតាមបណ្តាខេត្តភាគពាយ័ព្យខ្ញុំមានឱកាសជួបជាមួយគូសន្ទនាដទៃទៀតជាច្រើន រួមមានអង្គការមិនមែនរដ្ឋាភិ-

បាល សហជីពកម្មករ ដៃគូអភិវឌ្ឍន៍ និងក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស។ ខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកទាំងអស់ដែលបានចំណាយពេលវេលា មកធ្វើការចែករំលែកការយល់ដឹង និងព័ត៌មានផ្សេងៗជាមួយខ្ញុំ នៅក្នុងអំឡុងពេលនៃដំណើរបេសកកម្មនេះ ហើយជាពិសេស ក្នុងរយៈរយៈពេលប៉ុន្មានខែចុងក្រោយនេះ។

នៅក្នុងកិច្ចជំនួបប្រជុំជាមួយរដ្ឋមន្ត្រីនានានៃរដ្ឋាភិបាល ខ្ញុំមានក្តីរំភើបចិត្តជាខ្លាំងចំពោះឆន្ទៈរបស់ពួកគាត់ក្នុងការកំណត់បញ្ហាប្រឈមនានាដើម្បីបំពេញតាមបទដ្ឋានសិទ្ធិមនុស្សរបស់កម្ពុជា ហើយនិងការសំដែងការប្តេជ្ញាចិត្តរបស់ពួកគាត់ក្នុងការធ្វើឲ្យស្ថានភាពកាន់តែល្អប្រសើរឡើងថែមទៀត។ ខ្ញុំសង្ឃឹមថានឹងទទួលព័ត៌មានស្តីពីការធ្វើមូលដ្ឋានីយកម្មនៃគោលដៅអភិវឌ្ឍន៍សហប្រជាជាតិប្រកបដោយចីរភាព នៅពេលដែលមាន។ វាជាការសំខាន់ដែលថាកម្ពុជាបន្តប្រែក្លាយផែនការ និងយុទ្ធសាស្ត្រទៅជាវិធានការអនុវត្តប្រកបដោយវិជ្ជមាន ដើម្បីជម្រុញលើកកម្ពស់សិទ្ធិ និងសេរីភាពនៅក្នុងប្រទេសនេះ។

ខ្ញុំមានសេចក្តីរីករាយដែលដំណើរការចុះឈ្មោះបោះឆ្នោតមានការរីកចំរើនទៅមុខបានល្អ ហើយដែលចំនួនខ្ពស់នៃអ្នកបោះឆ្នោតត្រូវបានចុះឈ្មោះបោះឆ្នោតក្នុងការបោះឆ្នោតឆ្នាំ២០១៧។ នេះជាការលើកទឹកចិត្តថា ការបោះឆ្នោតឃុំ-សង្កាត់ នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ កន្លងទៅមានរបៀបរៀបរយល្អ និងប្រកបដោយសុខសន្តិភាព ដែលមានចំនួនប្រមាណជាកៅសិបភាគរយនៃអ្នកមានសិទ្ធិបោះឆ្នោត បានចេញទៅបោះឆ្នោត។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំនៅតែមានក្តីកង្វល់ចំពោះបរិយាកាសនៃការបំភិតបំភ័យ និងការគំរាមនៃអំពើហិង្សា ដោយរាប់ទាំងពីសំណាក់មន្ត្រីជាន់ខ្ពស់មួយចំនួន នៅមុនថ្ងៃបោះឆ្នោត និងនៅក្នុងប៉ុន្មានសប្តាហ៍បន្ទាប់ពីថ្ងៃបោះឆ្នោត។

## *២. បញ្ហាសំខាន់ៗ*

ខ្ញុំនៅតែមានក្តីកង្វល់អំពីស្ថានភាពលំបាកនៃក្រុមប្រជាជនដែលងាយរងគ្រោះជាច្រើននៅក្នុងប្រទេសកម្ពុជា។ ដូចដែលខ្ញុំបាននិយាយពីមុន វាជាការសំខាន់ដែលថានៅពេលដែលធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិប្រកបដោយចីរភាព រដ្ឋាភិបាលត្រូវធានាថា មិនមាននរណាម្នាក់ត្រូវបានគេទុកចោលដោយមិនគិតគូនោះឡើយ។ បើយោងតាមមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិសេរីភាពស្មើៗគ្នា ដោយគ្មានការរើសអើង។ ទោះយ៉ាងណាក៏ដោយ ក៏នៅតែមានឧទាហរណ៍នៃប្រជាជនជាច្រើនដែលស្ថិតក្នុងស្ថានភាពគួរឲ្យព្រួយបារម្ភ។

***កុមារ*** - កុមារ-នៅក្នុងអំឡុងពេលបំពេញបេសកកម្មនេះខ្ញុំបានផ្តោតការយកចិត្តទុកដាក់លើកុមារ។ ខ្ញុំស្វាគមន៍ចំពោះការដកចេញការបង់ថ្លៃសម្រាប់ការចុះបញ្ជីកំណើតរហូតដល់រយៈពេលសាមសិបថ្ងៃបន្ទាប់ពីថ្ងៃកើតរបស់ទារក ហើយខ្ញុំសូមជំរុញឲ្យមានការលើកកម្ពស់កាន់តែច្រើនថែមទៀតលើបញ្ហានេះនៅថ្នាក់ភូមិ និងឃុំ។ ការធានាឱ្យកុមារគ្រប់រូបបានចុះសំបុត្រកំណើត គឺជាកត្តាសំខាន់ក្នុងការទទួលស្គាល់សិទ្ធិកុមារ។ ចំពោះស្ថានភាពនៃការខ្វះប្រព័ន្ធទូលំទូលាយការពារកុមារ គណៈកម្មាធិការឃុំសង្កាត់ដើម្បីស្ត្រីនិងកុមារ (CCWC) គឺជាតួអង្គដ៏សំខាន់នៅក្នុងដែនសមត្ថកិច្ចរបស់ពួកគេនៅថ្នាក់មូលដ្ឋាន។ បើទោះជាការបណ្តុះប

ណ្តាលសមាជិកគណៈកម្មាធិការត្រូវបានធ្វើឡើងក៏ដោយ ក៏វាមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីផ្តល់ការការពារកុមារដោយឯករាជ្យទាំងស្រុងឡើយ។ កុមារកាន់តែច្រើនត្រូវបានទុកឲ្យនៅជាមួយសាច់ញាតិដែលជាចាស់ទុំ ខណៈដែលឪពុកម្តាយរបស់ពួកគេទៅបំរើការជាពលករចំណាកស្រុក ផ្លាស់ទៅធ្វើការនៅរោងចក្រ ឬការដ្ឋានសំណង់នៅកម្ពុជា ឬស្វែងរកការងារធ្វើនៅក្រៅប្រទេស។ កុមារទាំងនេះភាគច្រើនត្រូវបានគេបំពារបំពាន អ្នកដទៃទៀតបានធ្លាក់ខ្លួនប្រើប្រាស់គ្រឿងញៀននិងសារធាតុផ្សេងៗទៀត ហើយអ្នកខ្លះទៀតបានក្លាយជាអ្នករស់តាមចិញ្ចើមផ្លូវ។ កុមារដែលទទួលរងការរំលោភបំពានផ្លូវកាយ ឬផ្លូវចិត្តនៅក្នុងសហគមន៍ ឬគ្រួសារ ជាញឹកញាប់មិនមានមធ្យោបាយស្វែងរកជំនួយ ឬសុវត្ថិភាពទេ។ ខ្ញុំទទួលស្គាល់ថា រដ្ឋាភិបាលរៀបចំការស្ទង់មតិ និងផែនការសកម្មភាពស្តីពីហិង្សាទៅលើកុមារ ក៏ប៉ុន្តែដូចដែលខ្ញុំបានកត់សម្គាល់នៅពេលពិចារណាលើសិទ្ធិស្ត្រី ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារជារឿយៗនៅតែស្ថិតនៅក្នុងលំនៅឋានជាមួយជនល្មើស ហើយជនល្មើសមិនត្រូវបាននាំខ្លួនទៅកាត់ទោសតាមច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ។ ខ្ញុំសូមស្វាគមន៍ចំពោះផែនការសកម្មភាពដើម្បីលើកកម្ពស់កិច្ចគាំពារកុមារ ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយសហការជាមួយ អង្គការមូលនិធិរបស់អង្គការសហប្រជាជាតិសម្រាប់កុមារ (Unicef) អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ក៏ដូចជាកម្មវិធីភាពជាដៃគូសម្រាប់ការការពារកុមារ (3PC) មានគោលបំណងកាត់បន្ថយសាមសិបភាគរយនៃចំនួនកុមារនៅតាមសហគ្រាស នៅក្នុងខេត្តចំនួនប្រាំ ការធ្វើសមាហរណកម្មពួកគេទៅក្នុងសហគមន៍របស់ពួកគេ។ ខ្ញុំសង្ឃឹមថាផែនការនេះនឹងទទួលបានជោគជ័យ ហើយនិងអាចពង្រីកបន្ថែមទៅតាមបណ្តាខេត្តផ្សេងៗទៀត។ វាមានសារៈសំខាន់បំផុតដើម្បីធានាថាកុមារដែលបានត្រឡប់មកវិញត្រូវបានយកចិត្តទុកដាក់ថែទាំត្រឹមត្រូវ និងបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍របស់ពួកគេដោយអនុលោមតាមឧត្តមប្រយោជន៍របស់កុមារ។

មិនមានបណ្តាញទូលំទូលាយនៃបុគ្គលិកសង្គមកិច្ចរបស់រដ្ឋាភិបាលទេ។ ជាគោលគំនិត គេគួរតែមានយ៉ាងហោចណាស់ក៏មួយដែរក្នុងមួយឃុំៗ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំបានដឹងអំពីការងារការពារ និងការស្តារនីតិសម្បទាកុមារដែលបានធ្វើឡើងដោយបុគ្គលិកសង្គមដែលបានទទួលមូលនិធិពីអង្គការមិនមែនរដ្ឋាភិបាលនិងដោយទីភ្នាក់ងារផ្សេងៗរបស់អង្គការសហប្រជាជាតិ ហើយសូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥ ដើម្បីពិចារណាទទួលស្គាល់ លើកកម្ពស់ និងគាំទ្រយ៉ាងសកម្មដល់ការអប់រំការងារសង្គមកិច្ច និងកាលានុវត្តភាពមុខរបរ។ បុគ្គលិកសង្គមកិច្ចដែលបានបណ្តុះបណ្តាលអាចធ្វើការជាមួយគណៈកម្មាធិការឃុំសង្កាត់ដើម្បីស្ត្រី និងកុមារ នៅក្នុងឃុំ-សង្កាត់ ដើម្បីការពារកុមារ និងអ្នកដែលងាយរងគ្រោះ។

ខ្ញុំកត់សម្គាល់ឃើញមានការវិវឌ្ឍន៍ជាវិជ្ជមានទាក់ទងនឹងសុខភាពនិងការអប់រំរបស់កុមារ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលបានជម្រាបខ្ញុំថាអត្រាមរណៈរបស់ទារក និងកុមារ បន្តធ្លាក់ចុះ ការឆ្លងជំងឺកញ្ជ្រឹលត្រូវបានលុបបំបាត់ទាំងស្រុងក្នុងប្រទេសកម្ពុជា ការប្រើប្រាស់ការព្យាបាលប្រឆាំងមេរោគអេដស៍ដើម្បីទប់ស្កាត់ការចម្លងមេរោគ និងជំងឺអេដស៍ ពីមាតា ទៅទារក ក្នុងអំឡុងពេលកើត ហើយនិងការប្រើប្រាស់មូលនិធិសមធម៌ ដើម្បីធានាថាគ្រួសារក្រីក្រ និងកូនៗរបស់ពួកគាត់អាចទទួលបានសេវាថែទាំសុខភាព។ រដ្ឋាភិបាលក៏បានចាប់ផ្តើមដំណើរការកម្មវិធីចាក់ថ្នាំបង្ការប្រភេទមហារីកស្បូន (HPV) សម្រាប់កុមារី។ ទោះជាយ៉ាងណា

ក៏ដោយ រដ្ឋមន្ត្រីសក្រសួងសុខាភិបាល បានទទួលស្គាល់ថាខ្លួននៅមានការងារជាច្រើនទៀតក្នុងការកាត់បន្ថយអត្រាមរណភាពទារក និងកុមារ ហើយនិងការផ្តល់អាហារូបត្ថម្ភដល់កុមារ ជាពិសេសកុមាររស់នៅតាមសហគមន៍ជនបទ។ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានជូនជម្រាបខ្ញុំថា ប្រទេសកម្ពុជាមានសមភាពយេនឌ័រទាក់ទងនឹងការចុះឈ្មោះចូលរៀន និងការបញ្ចប់ការសិក្សា។ ប៉ុន្តែខ្ញុំកត់សម្គាល់ឃើញថា កុមារនៅក្នុងក្រុមជនជាតិដើមភាគតិច និងក្រុមជនជាតិភាគតិច នៅតែមិនទទួលបានផលប្រយោជន៍ពីការអប់រំ ដូចជាការផ្តល់ឲ្យមាន ការទៅប្រើប្រាស់បាន និងលក្ខណៈសម្បត្តិនៃសេវាដែលអាចទទួលយកបាន និងភាពបត់បែននៃសេវាអប់រំ។ នៅក្នុងវិស័យអប់រំ និងសុខាភិបាល ព័ត៌មានបានបង្ហាញច្បាស់ថាកុមារដែលមានពិការភាពមិនបានទទួលភាពស្មើគ្នាចំពោះលទ្ធភាពទទួលបានសេវាឡើយ។ ការបង្កភាពងាយស្រួលដល់ការទទួលយកសេវានៅក្នុងអគារផ្សេងៗនៅតែជាបញ្ហា ហើយការប្រើប្រាស់ភាសាសញ្ញា និងភាសាសម្រាប់មនុស្សពិការភ្នែកសម្រាប់គោលដៅជូនដំណឹងផ្សេងៗក៏នៅមានបញ្ហានៅឡើយ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានពិភាក្សាជាមួយខ្ញុំទាក់ទងនឹងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលត្រូវបានប្រកាសឲ្យប្រើកាលពីឆ្នាំមុន។ ពេលនេះគឺជាដំណាក់កាលអនុវត្តច្បាប់នេះ តាមរយៈការបង្កើតជាផែនការប្រតិបត្តិយុទ្ធសាស្ត្រ។ ជាមូលដ្ឋាន វាគឺជាដំណាក់កាលវិវឌ្ឍន៍ជាវិជ្ជមានមួយ។ ទោះជាយ៉ាងណាក៏ដោយ គេត្រូវយកចិត្តទុកដាក់ធានាថាច្បាប់នេះត្រូវបានយកមកអនុវត្តស្របទៅតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ និងសេចក្តីណែនាំផ្សេងៗទៀត ជាពិសេសការបំពាក់ធនធានគ្រប់គ្រាន់នៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន។ មជ្ឈមណ្ឌលស្តារនីតិសម្បទាដែលទើបបានបង្កើតថ្មីត្រូវរៀបចំឲ្យស្របនឹងបទដ្ឋានពាក់ព័ន្ធផ្សេងៗរបស់អង្គការសហប្រជាជាតិ។ ក្នុងអំឡុងពេលដែលខ្ញុំធ្វើទស្សនកិច្ចទៅកាន់មណ្ឌលអប់រំកែប្រែទី២ (ដែលជាពន្ធនាគារចម្បងក្នុងរាជធានីភ្នំពេញសម្រាប់ផ្ទុកជនជាប់ឃុំជាស្ត្រី និងអនីតិជន) នៅក្នុងសប្តាហ៍នេះ ខ្ញុំទទួលបានស្ថិតិថា អនីតិជនមានចំនួន ៤៨២ នាក់ (ក្នុងនោះស្រីមានចំនួន ៣៨ នាក់)។ កម្រិតនៃភាពចង្អៀតណែនក្នុងពន្ធនាគារតម្រូវឲ្យទណ្ឌិតស្ត្រីដែលជាអនីតិជន ត្រូវឃុំនៅក្នុងបន្ទប់ជាមួយគ្នានឹងទណ្ឌិតនីតិជនជាស្ត្រី។ ចំណុចនេះគឺផ្ទុយទៅនឹងបទដ្ឋានសិទ្ធិមនុស្សដែលកម្ពុជាយល់ព្រមទទួលយក។ ទន្ទឹមនឹងនេះ ខ្ញុំក៏ព្រួយបារម្ភផងដែរអំពីភាពយឺតយ៉ាវនៅក្នុងការកំណត់អាយុពិតប្រាកដរបស់អនីតិជនបន្ទាប់ពីត្រូវបានចាប់ខ្លួន ជាពិសេសការកំណត់ថាតើពួកគេមានអាយុក្រោម ឬលើអាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ ចំណែកឯកុមារដែលត្រូវបានចាត់ថ្នាក់ជាសាក្សី និងជាជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌវិញ ខ្ញុំបានទទួលព័ត៌មានថាមានតែតុលាការចំនួន ២ ឬ ៣ តែប៉ុណ្ណោះ ដែលមានអេក្រង់/ទូរទស្សន៍សម្រាប់សម្រួលឲ្យមានការផ្តល់សក្ខីកម្មពីចម្ងាយ ហើយដែលតាមរយៈវិធីនេះយើងអាចកាត់បន្ថយកុមារមិនឲ្យប្រឈមមុខផ្ទាល់ជាមួយជនសង្ស័យ និងអាចទប់ស្កាត់ភាពរងគ្រោះសាជាថ្មីបាន។

ខ្ញុំនៅមានការព្រួយបារម្ភថាអនីតិជនជាច្រើនត្រូវបានគ្រួសារបញ្ជូនទៅឃុំខ្លួន ឬរក្សាទុក នៅក្នុងមជ្ឈមណ្ឌលសំចត និងមណ្ឌលស្តារនីតិសម្បទា ហើយនិងស្ថាប័នផ្តល់សេវាថែទាំគ្រប់គ្រងផ្សេងៗ។ នៅពេលដែលទីកន្លែងទាំងនេះត្រូវបានបង្កើតឡើង អាចដោយសារយុទ្ធនាការបង្ក្រាបគ្រឿងញៀនក៏ដោយ ក៏ខ្ញុំនៅតែព្រួយបារម្ភជាពិសេសចំពោះកុមារខ្លះដែលមានពិការភាពធ្ងន់ធ្ងរ ហើយដែលនៅតែត្រូវបានបញ្ជូនទៅ

កាន់ទីកន្លែងទាំងនោះទៀត បើទោះបីជាពួកគេមិនមានប្រវត្តិប្រើប្រាស់គ្រឿងញៀន ឬសារធាតុញៀនក៏ដោយ។ ការណ៍នេះសបញ្ជាក់ឱ្យឃើញថាកម្ពុជាត្រូវការប្រព័ន្ធការពារសង្គម និងកុមារដែលមានលក្ខណៈទូលំទូលាយគ្រប់ជ្រុងជ្រោយ ហើយនិងបុគ្គលិកសង្គមកិច្ចដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវនៅគ្រប់ឃុំ-សង្កាត់ទាំងអស់។ ទោះជាយ៉ាងនេះក្តី វាក៏នៅមានបញ្ហាមួយទៀតគឺ ការឧបត្ថម្ភគាំទ្រចំពោះគ្រួសាររបស់កុមារដែលមានពិការភាពទាំងនោះ។

ទន្ទឹមនឹងការផ្តល់សេវាសាធារណៈភាគច្រើនត្រូវបានធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាល (ដែលការងារនេះ គួរតែរដ្ឋទេដែលជាអ្នកធ្វើ) យ៉ាងណាក៏ដោយ ក៏ខ្ញុំមានសេចក្តីរីករាយនៅពេលដឹងថា អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារផ្នែកសិទ្ធិកុមារអាចធ្វើសហប្រតិបត្តិការជាទូទៅជាមួយរដ្ឋាភិបាលបាន។

**ខ្ញុំជំរុញរដ្ឋាភិបាលឲ្យខិតខំធានាថា អភិក្រមផ្អែកលើសិទ្ធិកុមារត្រូវបានប្រើប្រាស់ក្នុងគ្រប់វិស័យទាំងអស់ទាក់ទងនឹងកុមារ។ កុមារដែលរស់នៅតាមផ្លូវ ស្នាក់នៅក្នុងកន្លែងផ្តល់សេវាថែទាំងគ្រប់គ្រង កុមារធ្វើចំណាកស្រុកតែឯង និងកុមាររងគ្រោះដោយសារការជួញដូរមនុស្ស គឺជាអ្នកដែលងាយរងគ្រោះបំផុត ហើយពួកគេត្រូវការអភិក្រមគ្រប់ជ្រុងជ្រោយមួយដើម្បីធានាបាននូវសុវត្ថិភាព និងសុខមាលភាពរបស់ពួកគេ។ ការស្តារនីតិសម្បទានិងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញចំពោះអនីតិជនដែលពាក់ព័ន្ធគ្រឿងញៀន អ្នកប្រើប្រាស់សារធាតុញៀន និងទណ្ឌិតជាអនីតិជនត្រូវតែបានដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងដោយប្រុងប្រយ័ត្ន និងទទួលបានការគាំទ្រជាដរាប ដើម្បីធានាឲ្យពួកគេទទួលបានការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មដ៏ពិតប្រាកដ។ វាគឺជារឿងចាំបាច់មួយក្នុងការធានាឲ្យបាននូវការលើកកម្ពស់ការយល់ដឹងគ្រប់ជ្រុងជ្រោយស្តីពីសិទ្ធិកុមារ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជនដល់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការទាំងអស់។**

***ជនជាតិដើមភាគតិច*** - ខ្ញុំមានសេចក្តីរីករាយដោយកត់សម្គាល់ថា ព្រឹត្តិការណ៍ដែលកត់សម្គាល់ទិវាអន្តរជាតិនៃជនជាតិដើមភាគតិចបានប្រព្រឹត្តទៅដោយសន្តិវិធី។ ខ្ញុំកត់សម្គាល់ផងដែរ អំពីការផ្តល់ការអប់រំដែលមានគុណភាព រួមមានកម្មវិធីអប់រំជាពីរភាសា ដែលបាននិងកំពុងដំណើរដោយក្រសួងអប់រំយុវជននិងកីឡា។ នៅមានបញ្ហាជាច្រើននៅឡើយលើការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ជនជាតិដើមភាគតិច។ ខ្ញុំរំលឹកឡើងវិញ ជាពិសេសជនជាតិដើមភាគតិចព័រ នៅខេត្តបាត់ដំបងដែលកម្មសិទ្ធិដីសហគមន៍របស់ពួកគាត់មិនអាចបន្តទៅមុខបាន ពីព្រោះទីតាំងដីនោះនៅកំពុងតែរង់ចាំឲ្យមានការបោសសម្អាតមីន ជនជាតិដើមភាគតិចស្ទួយ នៅក្នុងខេត្តកំពង់ស្ពឺ ដែលពាក្យសុំប័ណ្ណកម្មសិទ្ធិដីសហគមន៍របស់ពួកគាត់បាននិងកំពុងទទួលរងផលប៉ះពាល់ដោយសារបទបញ្ជាលេខ០០១ និងជនជាតិភាគតិច ព្នង នៅក្នុងខេត្តស្ទឹងត្រែង ដែលប្រឈមនឹងហានិភ័យនៃការបាត់បង់ផ្ទះសម្បែង ការចិញ្ចឹមជីវិត ព្រៃអារក្ស និងដីបញ្ចុះសពរបស់ខ្លួន ដោយទឹកជំនន់ដែលបណ្តាលមកពីគម្រោងវារីអគ្គីសនីសេសានក្រោម II ។ **ខ្ញុំសូមលើកឡើងជាថ្មីម្តងទៀតនូវអនុសាសន៍របស់ខ្ញុំថា រដ្ឋាភិបាលគួរពិចារណាអំពីការធ្វើឲ្យប្រព័ន្ធផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពសហគមន៍ (CLTs) មានលក្ខណៈសាមញ្ញនិងងាយស្រួល ដោយកាត់បន្ថយនីតិវិធីដែលបានតម្រូវមួយចំនួនចេញ និងធានាថាក្រុមជន**

**ជាតិដើមភាគតិចអាចទទួលអត្ថប្រយោជន៍ពីប្រព័ន្ធផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាព រួមទាំងរកកម្ចីតាមរយៈការប្រើប្រាស់ប័ណ្ណនេះជាសមូហភាពដើម្បីគម្រោងអភិវឌ្ឍន៍របស់ខ្លួន។**

*ជនដែលស្ថិតក្នុងស្ថានភាពរស់នៅតាមចិញ្ចើមផ្លូវ* - ខ្ញុំមានក្តីកង្វល់យ៉ាងខ្លាំងនៅពេលខ្ញុំបានទៅទស្សនាមជ្ឈមណ្ឌលសំចតពោធិសែនជ័យ( "ព្រៃស្ពឺ") នៅសប្តាហ៍នេះ ដោយដឹងថាមានមនុស្ស ៥៤៤ នាក់ ដែលរួមទាំងកុមារ ៦ នាក់ ផងត្រូវបានគេដាក់នៅទីនោះ។ នេះគឺជាការកើនឡើងមួយគួរឲ្យកត់សម្គាល់ចាប់ពីដំណើរទស្សនកិច្ចចុងក្រោយរបស់ខ្ញុំ ដែលគេបានប្រាប់ខ្ញុំថា មួយចំណែកដោយសារតែយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនរបស់រដ្ឋាភិបាល។ មិនឃើញមានការរីកចម្រើនទេនៅក្នុងមជ្ឈមណ្ឌលទាំងនោះ ក្រៅតែពីភាពកាន់តែចង្អៀតណែនជាមុន។ មនុស្សជាច្រើនដែលខ្ញុំបានជួប បានអះអាងថាត្រូវបានគេយកទៅដាក់នៅទីនោះដោយផ្ទុយពីឆន្ទៈរបស់ខ្លួន ហើយបានស្នាក់នៅទីនោះច្រើនជាងមួយសប្តាហ៍ ជារយៈពេលដែលចាំបាច់ដើម្បីពិនិត្យមើលឯកសារសម្គាល់អត្តសញ្ញាណ និងដើម្បីធានាសុវត្ថិភាពនិងការការពារចំពោះអ្នកដែលត្រូវបានដោះលែង។ អ្នកខ្លះបាននៅទីនោះអស់រយៈពេល ៦ខែ ឬច្រើនជាងនេះ។ ការនេះបង្កើតទៅជាការឃុំខ្លួនដោយបំពាន។ ទន្ទឹមនឹងនេះដែរ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រសួងសង្គមកិច្ច) បានពន្យល់ថា ទីតាំងថ្មីដែលបាននិងកំពុងសាងសង់នៅក្នុងខេត្តកណ្តាល នឹងជួយកាត់បន្ថយភាពចង្អៀតណែននៅឯព្រៃស្ពឺ និងផ្តល់ទីតាំងសមរម្យសម្រាប់ការស្តារនីតិសម្បទាអ្នកប្រើប្រាស់ថ្នាំញៀន និងសារធាតុញៀនដែលញៀននឹងសារធាតុទាំងនោះ និងផ្តល់កិច្ចគាំពារ និងព្យាបាលដល់ជនពិការសុខភាពផ្លូវចិត្ត។ មជ្ឈមណ្ឌលនេះនឹងមិនសង់រួចរាល់ទេរហូតដល់ចុងឆ្នាំនេះ ឬដើមឆ្នាំ២០១៨។ ដូច្នេះ មិនមានសញ្ញាបង្ហាញពីការថយចុះនៅថ្ងៃខាងមុខនូវភាពចង្អៀតណែននៃមជ្ឈមណ្ឌលព្រៃស្ពឺ ឬភាពប្រសើរឡើងនៃលក្ខខណ្ឌ ឬស្ថានភាពអ្នកជាប់ឃុំនៅទីនោះទេ។ **រដ្ឋាភិបាលត្រូវបានរំលឹកថា ការដាក់មនុស្សប្រឆាំងនឹងឆន្ទៈរបស់ពួកគេ មានន័យថាមណ្ឌលសំចតដែលតាមនិយមន័យជាអន្តរជាតិ គឺជាមណ្ឌលឃុំខ្លួន ហើយរដ្ឋាភិបាលត្រូវតែចាត់វិធានការដើម្បីធានាថាបទដ្ឋានអប្បរមាអំពីការប្រព្រឹត្តចំពោះអ្នកជាប់ឃុំដែលត្រូវបានបំពេញ។ នេះរួមបញ្ចូលទាំង ទឹកស្អាត ទទួលទានម្ហូបអាហារដែលមានជីវជាតិគ្រប់គ្រាន់ អនាម័យគ្រប់គ្រាន់ ខ្យល់អាកាស និងកិច្ចគាំពារសុខភាពគ្រប់គ្រាន់ រួមទាំងការគាំទ្រផ្នែកផ្លូវចិត្ត ក៏ដូចជាសិទ្ធិសួរសុខទុក្ខពីក្រុមគ្រួសារ និងសាច់ញាតិ មន្ត្រី ឬបុគ្គលិកសមស្របរបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ។ ខ្ញុំបានអំពាវនាវជាថ្មីដល់រដ្ឋាភិបាល ឲ្យអនុវត្តអនុសាសន៍របស់សន្និសីទជាតិស្តីពីបុគ្គលស្ថិតក្នុងស្ថានភាពនៅតាមចិញ្ចើមផ្លូវ (ខែធ្នូ២០១៥) និងដើម្បីធានាថាមជ្ឈមណ្ឌលសំចតមិនត្រូវបានគេប្រើប្រាស់ជាមណ្ឌលឃុំខ្លួនឡើយ តែជាទីកន្លែងផ្តល់នូវកិច្ចគាំពារសេវាកម្ម និងការជួយឧបត្ថម្ភចាំបាច់ដល់ជនដែលស្ថិតក្នុងស្ថានភាពនៅតាមចិញ្ចើមផ្លូវ។ ខ្ញុំសូមផ្តល់អនុសាសន៍ផងដែរថា រដ្ឋាភិបាលពិនិត្យឡើងវិញជាប្រព័ន្ធអំពីមូលដ្ឋានច្បាប់សម្រាប់ការឃុំខ្លួនពួកគេ កំណត់ឲ្យបានត្រឹមត្រូវ និងធ្វើការដើម្បីធានាការដោះលែងពួកគេ និងបញ្ជូនពួកគេត្រឡប់ទៅជួបជុំក្រុមគ្រួសារ និងសហគមន៍របស់ពួកគេវិញ។ ជំនួយឧបត្ថម្ភទាក់ទងនឹងបញ្ហានេះ អាចនឹងត្រូវបានស្នើសុំពីតួអង្គមកពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ រួមទាំងការិយាល័យOHCHR ផងដែរ។**

*អ្នកញៀនគ្រឿងញៀន និងសារធាតុញៀន* - ក្នុងខែមករា ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានចាប់ ផ្តើមយុទ្ធនាការប្រឆាំងគ្រឿងញៀនដំណាក់កាលទី១របស់ខ្លួន។ យុទ្ធនាការនេះ ឥឡូវកំពុងតែស្ថិត នៅក្នុង

ដំណាក់កាលទី២។ ខណៈដែលយុទ្ធនាការនេះហាក់បីដូចជាការផ្តួចផ្តើមជាវិជ្ជមានមួយដើម្បី លុបបំបាត់បញ្ហាគ្រឿងញៀនពីប្រទេសកម្ពុជា ក៏មានផលវិបាកដ៏គួរឲ្យព្រួយបារម្ភនៃការកើនឡើង យ៉ាងខ្លាំងនៃចំនួនអ្នកជាប់ឃុំនៅតាមពន្ធនាគារ មជ្ឈមណ្ឌលសំចត និងមជ្ឈមណ្ឌលស្តារនីតិសម្បទាផ្នែក គ្រឿងញៀននានា។ ទាំងនៅខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ លោកអភិបាលរងនៃខេត្តទាំងពីរនេះ បានអញ្ជើញខ្ញុំធ្វើទស្សនៈកិច្ចទៅកាន់មជ្ឈមណ្ឌលស្តារនីតិសម្បទាផ្នែកគ្រឿងញៀនរបស់ពួកគាត់។ ខ្ញុំមានពេលទទួលការអញ្ជើញនៅស៊ីសុផុន «ហើយក៏រូតរះធ្វើដំណើរបន្តទៅកាន់មជ្ឈមណ្ឌលជីវិតថ្មី ដោយបានមើលកន្លែងខ្លះៗនៅក្នុងមជ្ឈមណ្ឌលនេះ។ ខ្ញុំក៏បានធ្វើទស្សនៈកិច្ច ទៅកាន់មជ្ឈមណ្ឌលសំចតពោធិសែនជ័យ (ព្រៃស្ពឺ) និងទៅកាន់មណ្ឌលអប់រំកែប្រែទី ១ និងទី២ ផងដែរ។ ខ្ញុំមានការព្រួយបារម្ភចំពោះចំនួនមនុស្សដ៏ច្រើនដែលកំពុងជាប់ឃុំដោយសារតែយុទ្ធនាការប្រឆាំងគ្រឿងញៀន និងកត់សំគាល់ថា ប្រសិនបើមនុស្សទាំងនោះ ត្រូវបានគេឃាត់ទុកផ្ទុយពីឆន្ទៈរបស់ពួកគេ ទីកន្លែងទាំងនោះគឺជាទីឃុំឃាំង ដោយយោងតាមបទដ្ឋានសិទ្ធិមនុស្សដែលទទួលស្គាល់ដោយប្រទេសកម្ពុជា។ កម្រិតនៃភាពចង្អៀតណែនបែបនេះនៅតាមទីកន្លែងឃុំឃាំងជាច្រើន គឺជាការរំលោភបទដ្ឋានរបស់ប្រទេសកម្ពុជា និងបទដ្ឋានអន្តរជាតិ។ អាហារគ្រប់គ្រាន់ ទឹកស្អាត សម្ភារៈអនាម័យ ឱកាសហាត់ប្រាណ ខ្យល់អាកាសចេញចូលបន្ទប់ ការថែទាំសុខភាព កំពុងតែមានការខ្វះខាត។ ប្រព័ន្ធនេះមិនអាចឆ្លើយតបទៅនឹងបញ្ហាដ៏ច្រើនបែបនេះបានទេ។ ជាការសំខាន់ត្រូវធានាថា មានការបណ្តុះបណ្តាល និងការអប់រំគ្រប់គ្រាន់ ជាពិសេសសម្រាប់យុវជន ដើម្បីធ្វើឲ្យការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ប្រកបដោយជោគជ័យ។

យោងតាមក្រសួងសុខាភិបាល មកដល់បច្ចុប្បន្ននេះ មានមជ្ឈមណ្ឌលថែទាំសុខភាពចំនួន ១៧៧ ដែលមានបុគ្គលិកទទួលការបណ្តុះបណ្តាលដើម្បីធ្វើការជាមួយអ្នកញៀនគ្រឿងញៀន។ កាលពីខែមុន មានមនុស្សចំនួន ៥២២ នាក់ បានទទួលការពិនិត្យសុខភាព និងការព្យាបាលនៅតាមមជ្ឈមណ្ឌលទាំងនេះ ដែលក្នុងចំណោមអ្នកទាំងអស់នោះមានបុរស ចំនួន ៩៦%។ ខ្ញុំយល់ស្របជាមួយក្រសួងដែលថា វាគឺជាការចាំបាច់ក្នុងការធ្វើការងារលើការផ្តល់ប្រឹក្សាយោបល់ និងវិធីព្យាបាលដែលត្រូវបានទទួលស្គាល់ ផ្សេងៗ ដើម្បីកាត់បន្ថយចំណង់ប្រើប្រាស់គ្រឿងញៀនដោយសារតែមានការរីករាលដាលនៃការប្រើប្រាស់មេតាហ្វេតាមីន។ មជ្ឈមណ្ឌលទាំងនេះ ជួយគាំទ្រដល់អ្នកដែលញៀនគ្រឿងញៀនដែលរស់នៅតាមសហគមន៍។

**ខ្ញុំសូមជម្រុញដល់រាជរដ្ឋាភិបាល ឲ្យផ្តល់ធនធានគ្រប់គ្រាន់ដើម្បីសាងសង់មជ្ឈមណ្ឌលស្តារនីតិសម្បទា និងមជ្ឈមណ្ឌលសំចតថ្មី ដើម្បីធានាថា មជ្ឈមណ្ឌលទាំងនេះឆ្លើយតបត្រឹមត្រូវ ទៅតាមបទដ្ឋានអប្បរមាដែល មានចែងក្នុងលិខិតុបករណ៍របស់អង្គការសហប្រជាជាតិ និងធានាថា មជ្ឈមណ្ឌលទាំងនោះផ្តល់ការព្យាបាល និងវិធីព្យាបាលសមស្រប។ យុទ្ធនាការប្រឆាំងគ្រឿងញៀន គួរតែត្រូវបានពិនិត្យឡើងវិញឲ្យបានទៀងទាត់ ហើយដោយអនុម័តតាមអភិក្រមសិទ្ធិមនុស្ស។ ការបណ្តុះបណ្តាល និងការអប់រំសមស្រប គួរតែត្រូវបានផ្តល់ដោយក្រសួងការងារ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ព្រមទាំងពិចារណាផ្តល់ឱកាសអប់រំផ្សេងៗតាមរយៈ ក្រសួងអប់រំ យុវជន និងកីឡា។ ខ្ញុំសូមគាំទ្រដល់កម្មវិធីលើកកម្ពស់ការយល់ដឹងអំពីការប្រើប្រាស់គ្រឿងញៀន និងសារធាតុញៀន ដែលកំពុងតែអនុវត្តតាមរយៈក្រសួងអប់រំ យុវជន និងកីឡា និងសូមស្នើសុំដល់ រាជរដ្ឋាភិបាលបន្តពង្រឹងដល់កម្មវិធីនេះ និងការងាររបស់ក្រសួងសុខាភិបាលនៅតាម**

**មជ្ឈមណ្ឌលថែទាំ សុខភាពនានា ដើម្បីពង្រីកការលើកកម្ពស់ការយល់ដឹងនៅតាមសហគមន៍ ក៏ដូចជាក្នុងចំណោមអ្នកទាំងឡាយ ដែលធ្វើការឃុំខ្លួន និងព្យាបាលអ្នកញៀនគ្រឿងញៀន និងសារធាតុញៀន។ ក្នុងពេលជាមួយគ្នានេះ ដៃរការចេញចូលជួបអ្នកដែលជាប់ឃុំគួរតែបើកចំហរឲ្យបានពេញលេញសម្រាប់ក្រុមគ្រួសារ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងអ្នកផ្សេងទៀតដែលអាចផ្ដល់ការគាំទ្រ។**

**អ្នកស្វែងរកសិទ្ធិជ្រកកោន៖** ខ្ញុំមានការព្រួយបារម្ភចំពោះស្ថានភាពរបស់ជនជាតិម៉ុងតាញ៉ាចំនួន ៣៦ នាក់ ដែលឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានស្វះស្វែងរកដំណោះស្រាយឱ្យពួកគេអាចធ្វើដំណើរទៅកាន់ប្រទេសផ្សេងក្រៅពីប្រទេសកម្ពុជា ដោយផ្អែកលើស្ថានភាពតឹងតែងនៃការទាមទារសិទ្ធិជ្រកកោនរបស់ពួកគេ។ រហូតមកទល់ពេលបច្ចុប្បន្ន រដ្ឋាភិបាលកម្ពុជាមិនទាន់បានយល់ព្រមសម្របសម្រួលឱ្យពួកគេបានឆ្លងកាត់ទៅកាន់ប្រទេសទីបីដែលជាទីមានសុវត្ថិភាពសម្រាប់ពួកគេនៅឡើយទេ។ **ខ្ញុំស្នើឱ្យរដ្ឋាភិបាលកម្ពុជាធ្វើទំនាក់ទំនងជាមួយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ដើម្បីធានាថាជនជាតិម៉ុតាញ៉ាទាំង ៣៦ នាក់ ដែលត្រូវការការពារជាអន្តរជាតិក្នុងឋានៈជាជនភៀសខ្លួនមិនត្រូវបានគេបញ្ជូនត្រឡប់ទៅកាន់ប្រទេសវៀតណាម។**

***នីតិរដ្ឋ និងការគ្រប់គ្រងវិស័យយុត្តិធម៌***

ខ្ញុំបានជួបជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រកបដោយភាពវិជ្ជមាន និងស្ថាបនា។ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានដឹងថាក្រសួងយុត្តិធម៌បានបង្កើនថវិកា ហើយបច្ចុប្បន្ននេះកំពុងធ្វើឲ្យមានភាពជឿនលឿនទៅលើការផ្តួចផ្តើមគំនិតមួយចំនួនដែលធ្លាប់បានពិភាក្សាជាយូរមកហើយ។ ជាពិសេស ខ្ញុំកត់សម្គាល់ឃើញពីភាពជឿនលឿនទៅលើការពង្រឹងការរៀបចំអង្គការតុលាការ ដើម្បីជួយកសាងមូលដ្ឋានស្ថាប័នតុលាការឲ្យកាន់តែមានប្រសិទ្ធភាពឡើងថែមទៀត។ ខ្ញុំយល់ថា ច្បាប់គ្រឹះទាំងបីអាចនឹងត្រូវធ្វើវិសោធនកម្ម ហើយខ្ញុំសូមលើកទឹកចិត្តដល់ក្រសួងយុត្តិធម៌ដើម្បីធ្វើឲ្យប្រាកដប្រជាថា ការធ្វើវិសោធនកម្មណាមួយ ត្រូវឆ្លុះបញ្ចាំងពីកង្វល់ទាំងឡាយ ដែលត្រូវបានលើកឡើង ហើយត្រូវឲ្យស្របតាមបទដ្ឋានសិទ្ធិមនុស្សនានា ដែលប្រព្រឹត្តទៅដើម្បីពង្រឹងនិងមិនធ្វើឲ្យចុះខ្សោយដល់ឯករាជភាពនៃស្ថាប័នតុលាការឡើយ។ ខ្ញុំសូមស្វាគមន៍ផងដែរ នូវការតំឡើងប្រព័ន្ធទិន្នន័យចុះបញ្ជីសំណុំរឿងព្រហ្មទណ្ឌតាមប្រព័ន្ធអេឡិចត្រូនិច។ មានសំណុំរឿងព្រហ្មទណ្ឌចំនួនប្រហែល ២៣,០០០ ករណី ត្រូវបានចុះបញ្ជីទៅក្នុងប្រព័ន្ធទិន្នន័យនេះ ហើយក្រសួងយុត្តិធម៌កំពុងរៀបចំផែនការដើម្បីតំឡើងប្រព័ន្ធទិន្នន័យមេមួយដើម្បីចុះបញ្ជីសំណុំរឿងព្រហ្មទណ្ឌ បន្ទាប់មកធ្វើការចុះបញ្ជីសំណុំរឿងរដ្ឋប្បវេណី ហើយនឹងតំឡើងប្រព័ន្ធគ្រប់គ្រងសំណុំរឿងតាមប្រព័ន្ធអេឡិចត្រូនិចឲ្យបានទូលំទូលាយ។ នេះគឺជាចន្លួមួយឆ្ពោះទៅរកតម្លាភាពឲ្យកាន់តែប្រសើរថែមទៀត ក្នុងប្រព័ន្ធយុត្តិធម៌។ ខ្ញុំសូមស្វាគមន៍ចំពោះការកើនឡើងនូវការប្រើប្រាស់រូបមន្តថ្មីនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ប៉ុន្តែមានការព្រួយបារម្ភថា ការប្រើប្រាស់រូបមន្តថ្មីនៃដីកាសម្រេចឃុំខ្លួននេះ មិនទាន់មានភាពត្រឹមត្រូវនៅឡើយទេ។ ខ្ញុំនៅតែមានការព្រួយបារម្ភថា ការឃុំខ្លួនបណ្តោះអាសន្ននៅតែបន្តប្រើប្រាស់ស្ទើរតែគ្រប់ករណី ជាពិសេសនៅពេលដែលប្រព័ន្ធគ្រប់គ្រងពន្ធនាគារ មានភាពចង្អៀតណែនប្រកបដោយគ្រោះថ្នាក់។ ខ្ញុំសូមស្វាគមន៍ចំពោះផែនការទាំងឡាយលើការងារយុទ្ធនាការសំរាប់លើកកំពស់

ការយល់ដឹងក្នុងចំណោមអ្នកទាំងឡាយណាដែលត្រូវដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយសារការចាប់ខ្លួនហើយរង់ចាំសវនាការ។ ខ្ញុំសូមស្វាគមន៍ផងដែរចំពោះផែនការទាំងឡាយ សម្រាប់គម្រោងសាកល្បងមួយ ស្តីពីការដាក់ទោសតាមជម្រើសផ្សេងក្រៅពីពន្ធនាគារនៅខេត្តបាត់ដំបង ដែលជាដំណាក់កាលដំបូងឆ្ពោះទៅរកការបង្កើននូវការប្រើប្រាស់ជម្រើសផ្សេងក្រៅពីការឃុំខ្លួន ដូចមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានធានាថា តារាងកំណត់តម្លៃប្រាក់ប្រដាប់ក្តី និងតម្លៃសេវាពាក់ព័ន្ធទាំងអស់ នឹងត្រូវដាក់ឲ្យសាធារណៈជនមើលនៅគ្រប់តុលាការ។ ការធ្វើបែបនេះអាចកាត់បន្ថយបាននូវតម្លៃសេវាបន្ថែមក្រៅផ្លូវការ ដែលត្រូវបានកំណត់សម្រាប់កិច្ចការពាក់ព័ន្ធនឹងតុលាការ។ ខ្ញុំមានការព្រួយបារម្ភចំពោះរបាយការណ៍របស់សហគមន៍ដែលស្វែងរកយុត្តិធម៌តាមមធ្យោបាយដោយខ្លួនឯង។ ការអនុវត្តបែបនេះមិនអាចទទួលយកបានទេ - វាឆ្លុះបញ្ចាំងពីតម្រូវការឲ្យមានការពង្រឹងប្រព័ន្ធតុលាការ និងកសាងទំនុកចិត្តលើឯករាជភាពរបស់តុលាការ។ ខ្ញុំសូមស្វាគមន៍ចំពោះការបង្កើនថវិកាដល់ជំនួយផ្នែកច្បាប់ការពារជនក្រីក្រ ប៉ុន្តែខ្ញុំមានការព្រួយបារម្ភចំពោះការខ្វះខាតមេធាវី និងឆន្ទៈក្នុងការការពារក្តីឲ្យបុគ្គលដែលងាយរងគ្រោះបំផុតដែលត្រូវចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ ខ្ញុំសូមស្វាគមន៍ផងដែរចំពោះផែនការទាំងឡាយ ដើម្បីអនុវត្តគំរោងសាកល្បងនូវយន្តការដំណោះស្រាយវិវាទតាមជម្រើសផ្សេង នៅតាមបណ្តាខេត្តជាច់ស្រយាល បើទោះបីជាមានការបញ្ជាក់ជាថ្មីថា យន្តការបែបនេះមិនសមស្របនឹងបទល្មើសមួយចំនួន រាប់ទាំងអំពើហិង្សាក្នុងគ្រួសារក៏ដោយ។

បញ្ហាបន្ទាន់បង្ខំនៃភាពចង្អៀតណែនក្នុងពន្ធនាគារ ត្រូវបានលើកឡើងរួចមកហើយ។ នៅពេលធ្វើទស្សនកិច្ចទៅកាន់មណ្ឌលអប់រំកែប្រែទី១ និងមណ្ឌលអប់រំកែប្រែទី២ ខ្ញុំមានសេចក្តីសោមនស្សរីករាយដោយកត់សម្គាល់ឃើញថា ប័ណ្ណព័ត៌មានត្រូវបានដាក់បង្ហាញដល់សាធារណៈជន ដោយកត់សម្គាល់អំពីសិទ្ធិរបស់ជនជាប់ឃុំ និងសិទ្ធិរបស់អ្នកមកសួរសុខទុក្ខ បើទោះបីជាប័ណ្ណទាំងនេះជាញឹកញាប់ សរសេរតែជាភាសាអង់គ្លេសក៏ដោយ។ ប៉ុន្តែខ្ញុំមានការព្រួយបារម្ភថា នៅពេលកំពុងធ្វើទស្សនកិច្ចមណ្ឌលអប់រំកែប្រែទី១ មន្ត្រីមួយរូបរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជាដែលអមដំណើរខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យចូលឡើយ។ ខ្ញុំមានការព្រួយបារម្ភផងដែរថា រូបខ្ញុំក៏មិនត្រូវបានអនុញ្ញាតឲ្យធ្វើការសំភាសន៍ដោយសម្ងាត់ជាមួយជនជាប់ឃុំ ទាំងនៅមណ្ឌលអប់រំកែប្រែទី១ និងមណ្ឌលអប់រំកែប្រែទី២។ ការបដិសេធដដែលៗមិនអនុញ្ញាតឲ្យមានការសម្ភាសន៍សម្ងាត់នេះ គឺផ្ទុយនឹងអាណត្តិការងារដែលតាមលក្ខខ័ណ្ឌនេះប្រទេសកម្ពុជាព្រមព្រៀងទទួលយកដំណើរទស្សនកិច្ចរបស់ខ្ញុំ សូមផ្តល់អនុសាសន៍ថា គម្រោងសាកល្បងដែលបានគ្រោងទុកស្តីពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ការផ្តន្ទាទោសដោយមិនឃុំខ្លួន និងការដោះស្រាយជម្លោះតាមជម្រើសផ្សេង ត្រូវបានអនុវត្តពិនិត្យឡើងវិញនិងត្រូវបានពង្រីក ទៅតាមការសមស្រប។ បញ្ហានៃភាពចង្អៀតណែននៅក្នុងពន្ធនាគារត្រូវតែលើកមកពិភាក្សារកដំណោះស្រាយឲ្យបានឆាប់។ ខ្ញុំសូមបញ្ជាក់ឡើងវិញនូវអនុសាសន៍របស់ខ្ញុំកាលពីពេលមុនៗ ដែលគូសបញ្ជាក់ថា ការឃុំខ្លួនគួរតែត្រូវបានអនុវត្តនៅពេលណាចាំបាច់បំផុតប៉ុណ្ណោះ។ ខ្ញុំសូមផ្តល់អនុសាសន៍ផងដែរថា គ្រប់តុលាការត្រូវតែបង្ហាញឲ្យច្បាស់ពីកម្រៃណាមួយដែលតម្រូវឲ្យគេបង់។ នៅពន្ធនាគារ ខ្ញុំសូមរំលឹកអនុសាសន៍របស់ខ្ញុំថា ប័ណ្ណព័ត៌មានដែលពន្យល់ពីនីតិវិធីចុះទៅសួរសុខទុក្ខនៅពន្ធនាគាររួមទាំងការហាមប្រាមលើការបង់ប្រាក់ ត្រូវតែបានដាក់បង្ហាញយ៉ាងច្បាស់ជាភាសាខ្មែរនៅច្រកចូល និងនៅតាមបន្ទប់ឃុំឃាំងនីមួ

យ១។ ដើម្បីសម្រេចគោលដៅនេះ ខ្ញុំសូមឲ្យការិយាល័យOHCHR ផ្តល់នូវប័ណ្ណព័ត៌មានដែលបោះពុម្ភដោយក្រសួងមហាផ្ទៃ/ការិយាល័យ OHCHR/IBJ ដល់គ្រប់ពន្ធនាគារ។

*លំហប្រជាធិបតេយ្យ*

ខ្ញុំមានសេចក្តីរីករាយដោយកត់សម្គាល់ឃើញមានការដោះលែងមន្ត្រីអាដហុក៤នាក់ និងអគ្គលេខាធិការរងម្នាក់នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅខែមិថុនា ទោះបីជាខ្ញុំមានការព្រួយបារម្ភថាពួកគេនៅតែស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក៏ដោយ។ ប្រេវ៉ាឡង់នៃការឃុំខ្លួនបណ្តោះអាសន្ននិងនិន្នាការចេះតែកើនឡើងនៃការគ្រប់គ្រងដោយច្បាប់នៅកម្ពុជា គឺជាប្រការគួឲ្យព្រួយបារម្ភ។ ទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌចែងពីអាជ្ញាយុកាលសម្រាប់ប្រភេទខុសៗគ្នានៃបទល្មើសក៏ដោយក៏រឿងទាំងនេះត្រូវបានរំខានដោយទង្វើនៃការចោទប្រកាន់ ឬការស៊ើបអង្កេត។ មានការព្រួយបារម្ភថា បទប្បញ្ញត្តិបែបនេះ អាចអនុញ្ញាតឲ្យមានការចោទប្រកាន់អន្ទោលតាមនរណាម្នាក់ដោយគ្មានកំណត់ ដោយបំពានលើកាតព្វកិច្ចដែលត្រូវបានជំនុំជម្រះដោយគ្មានការពន្យារពេលមិនត្រឹមត្រូវ - ច្បាប់មិនបានចែងច្បាស់លាស់ពីរយៈពេលកំណត់សម្រាប់ការស៊ើបអង្កេត កាលណាជនជាប់ចោទមិនស្ថិតនៅក្នុងការឃុំខ្លួន។ មានឧទាហរណ៍ជាច្រើនរួមទាំងករណីរបស់សកម្មជនដីធ្លីគឺ លោកស្រី ទេព វណ្ណី ដែលខ្ញុំបានជួប និងសកម្មជនសហជីព ហើយនិងសកម្មជននយោបាយជាដើម។

គ្រប់ច្បាប់ទាំងអស់គួរត្រូវបានអនុវត្តឲ្យបានត្រឹមត្រូវ និងស្មើៗគ្នាចំពោះគ្រប់មនុស្សទាំងអស់ដោយគ្មានការរើសអើងទោះផ្អែកលើមូលហេតុអ្វីក៏ដោយ។ អ្នកការពារសិទ្ធិមនុស្សនៅតែត្រូវបានគេដៅជាមុខសញ្ញាកាន់តែច្រើនឡើងៗ។ ច្បាប់ជាច្រើនប្រភេទត្រូវបានយកមកប្រើប្រាស់ដើម្បីរឹតត្បិតការរិះគន់ប្រឆាំងរដ្ឋាភិបាល ហើយការបង្អាក់ការពិភាក្សាដេញដោលផ្នែកនយោបាយនៅតែបន្តកើតមានឡើងជាច្រើន។ ការធ្វើបាតុកម្មដោយសន្តិវិធី និងការពិភាក្សាដេញដោលជាសាធារណៈ រួមទាំងប្រធានបទស្តីពីសិទ្ធិមនុស្ស និងការងារសង្កេតការបោះឆ្នោត ហើយនិងការលើកឡើងឲ្យរដ្ឋាភិបាលចេះទទួលខុសត្រូវ មិនមែនជាសកម្មភាពដែលមានលក្ខណៈផ្ទុយនឹងអធិបតេយ្យភាពរបស់រដ្ឋ ឬជាការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈឬសន្តិសុខជាតិឡើយ។ ខ្ញុំនៅតែព្រួយបារម្ភថា ច្បាប់ស្តីការធ្វើបាតុកម្មដោយសន្តិវិធី និងសេចក្តីណែនាំអនុវត្តច្បាប់នេះនៅមិនទាន់ត្រូវបានអនុវត្តឲ្យបានគត់មត់នៅឡើយនៅថ្នាក់មូលដ្ឋាន ហើយក្រសួងមហាផ្ទៃថែមទាំងបានតម្រូវឲ្យអង្គការសង្គមស៊ីវិលរាយការណ៍សកម្មភាពទាំងអស់របស់ពួកគេ រួមទាំងសកម្មភាពអប់រំបណ្តុះបណ្តាលផងទៅឲ្យអាជ្ញាធរឃុំ និងស្រុក។ តាមតថភាពជាក់ស្តែង យើងឃើញថាទោះបីជាវាគ្រាន់តែជាការប្រារព្ធទិវាចងចាំ/រំឭកខួបផ្សេងៗក៏នៅតែតម្រូវឲ្យមានការរាយការណ៍ផងដែរ។ ការរឹតត្បិតដោយមិនចាំបាច់ ចំពោះសេរីភាពប្រមូលផ្តុំបានបង្អាក់ដល់សកម្មភាពស្របច្បាប់ជាច្រើនរបស់សង្គមស៊ីវិល។ កម្ពុជាគួរតែជាប្រទេសមួយប្រកាន់យកនូវរបបប្រជាធិបតេយ្យសេរីពហុបក្សដ៏រស់រវើក ហើយដែលលើកទឹកចិត្ត (មិនមែនដាក់ទណ្ឌកម្មឡើយ) ឲ្យមានការពិភាក្សាដេញដោល និងការបញ្ចេញមតិដោយសមហេតុផល ព្រោះថាការពិភាក្សាប្រកបដោយផ្លែផ្កាចំពោះរឿងនយោបាយ គឺជាការត្រួសត្រាយផ្លូវមួយឈានទៅរកការបោះឆ្នោតដោយត្រឹមត្រូវពេញលេញ។ វាគឺជារឿងពិបាកយល់នៅពេលដែលអង្គការសង្គមស៊ីវិល ហើយនិងសហជីព

ត្រូវបានតម្រូវឲ្យមានអព្យាក្រឹតភាពផ្នែកនយោបាយ។ ផ្ទុយទៅវិញមន្ត្រីរាជការ ហើយនិងកងកម្លាំងនគរបាល និងយោធាឯណោះទៅវិញទេ ដែលត្រូវប្រកាន់ជំហរអព្យាក្រឹតចំពោះរឿងនយោបាយ។

ទោះបីជាមានភាពជោគជ័យនៃការបោះឆ្នោតឃុំ/សង្កាត់ក៏ដោយ ក៏ខ្ញុំនៅតែមានកង្វល់អំពីវោហាសាស្ត្របែបហិង្សាដែលសម្តែងឡើងដោយសមាជិករដ្ឋាភិបាលនិងយោធា។ មតិយោបល់បែបនេះមិនគួរត្រូវបានធ្វើឡើងដោយរដ្ឋមន្ត្រីនៃរដ្ឋាភិបាលឡើយ សូម្បីតែនៅក្នុងភាពជាឯកជនក៏ដោយ។ មតិយោបល់បែបនេះមិនត្រូវឲ្យមាននៅក្នុងសង្គមដែលមានសន្តិភាពមួយ ដូចជានៅក្នុងប្រទេសកម្ពុជា ដែលនៅឱិតដាមដោយស្លាកស្នាមនៃប្រវត្តិសាស្ត្រដ៏ចលាចលរបស់ខ្លួន។ ខ្ញុំបានកត់សម្គាល់នូវ វិសោធនកម្មជាច្រើនលើច្បាប់ស្តីពីគណបក្សនយោបាយ ជាពិសេសលើការសើរើឡើងវិញដែលហាមឃាត់គណបក្សមួយមិនឲ្យប្រើរូបភាព សំឡេង ឬឯកសារជាលាយលក្ខណ៍អក្សរ ឬសកម្មភាពនានានៃជនដែលត្រូវបានកាត់ទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិម។ អ្នកដឹកនាំពិភពលោកល្បីៗជាច្រើន ទាំងក្នុងអតីតកាល និងបច្ចុប្បន្នកាល ត្រូវបានគេផ្តន្ទាទោសពីបទល្មើសនៅពេលណាមួយ រាប់ទាំងនៅក្នុងតំបន់នេះផងដែរ។ ខ្ញុំសូមស្វាគមន៍ចំពោះកិច្ចសហការរបស់អង្គការមិនមែនរដ្ឋាភិបាល ដូចជាបន្ទប់ស្ថានការណ៍ និងការងារសង្កេតការណ៍យ៉ាងទូលំទូលាយលើដំណើរការបោះឆ្នោតនៅខែមិថុនាឆ្នាំ២០១៧។ បន្ទប់ស្ថានការណ៍មិនមែនជាអង្គការក្រៅរដ្ឋាភិបាលមួយនោះទេ ដូច្នេះបន្ទប់ស្ថានការណ៍មិនមានកាតព្វកិច្ចទៅតាមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលឡើយ។

ស្ថានភាពទូទៅនៅក្នុងប្រទេសនៅតែមានភាពតានតឹង។ ប្រទេសកម្ពុជាហាក់ដូចជាកំពុងខិតទៅជិតស្ថានភាពគ្រោះថ្នាក់។ ចំណាត់ការផ្លូវច្បាប់ជាច្រើនប្រឆាំងនឹងអ្នកនយោបាយ ការចោទប្រកាន់ពីការរំលោភលើអព្យាក្រឹត្យខាងនយោបាយរបស់អង្គការមិនមែនរដ្ឋាភិបាល ការឃុំខ្លួនបណ្តោះអាសន្នចេះតែបន្ត ការបំភិតបំភ័យ និងការភ័យខ្លាច ដើរមិនស្របគ្នាជាមួយនឹងបរិយាកាសមួយដែលនាំឲ្យមានការបោះឆ្នោតដោយសេរីនោះទេ។ ខ្ញុំសូមជម្រុញរាជរដ្ឋាភិបាលឲ្យធានាថា គ្រប់ភាគីទាំងអស់មានលទ្ធភាពក្នុងការសួរដេញដោលគ្នានិងការពិភាក្សាគ្នាដោយចំហលើបញ្ហាដែលជាកង្វល់របស់ប្រជាជនកម្ពុជាទាំងអស់។

## ៣. *សេចក្តីបញ្ចប់*

ជាការកត់សម្គាល់ របាយការណ៍ឆ្នាំ២០១៧ របស់ខ្ញុំដែលដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ត្រូវបានសរសេរនៅក្នុងខែឧសភា ហើយបានដាក់ជូនអង្គការសហប្រជាជាតិនៅក្នុងទីក្រុងហ្សឺណែវ នៅដើមខែមិថុនា ឆ្នាំ២០១៧។ យោងតាមនីតិវិធីដែលកំពុងអនុវត្ត របាយការណ៍នោះត្រូវបានចែករំលែកជាមួយរដ្ឋាភិបាល បន្ទាប់មកវានឹងត្រូវបន្តនីតិវិធីស្របតាមពិធីសារកែសម្រួលនិងបកប្រែរបស់អ.ស.ប។ វានឹងត្រូវចេញផ្សាយនាពេលឆាប់ៗនេះ ក្នុងឋានៈជាឯកសារ អ.ស.ប លេខA/HRC/36/61។ ខ្ញុំនឹងទៅចូលរួមជាមួយក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប នៅទីក្រុងហ្សឺណែវ នៅចុងខែកញ្ញាឆ្នាំ២០១៧ នេះ។ នៅពេលនោះ ខ្ញុំនឹងបង្ហាញរបាយការណ៍ និងធ្វើបច្ចុប្បន្នភាពដល់ក្រុមប្រឹក្សាសិទ្ធិមនុស្សអំពីស្ថានភាពចាប់តាំងពីខែមិថុនាមក និងរាយការណ៍ដោយផ្ទាល់មាត់អំពីបេសកកម្មបច្ចុប្បន្ននេះរបស់ខ្ញុំ។ ព័ត៌មានស្តីពីស្ថានភាពបន្ទាប់ពីការបោះឆ្នោតឃុំសង្កាត់ និងបេសកកម្មនេះ នឹងមាននៅក្នុងរបាយការណ៍ឆ្នាំ ២០១៨។

ខ្ញុំសង្ឃឹមថាដើម្បីធ្វើដំណើរឆ្ពោះទៅមុខ ប្រទេសកម្ពុជានឹងខិតចេញពីស្ថានភាពគ្រោះថ្នាក់ ដោយមិនឲ្យមានទៀតនូវការគំរាមកំហែងនៃអំពើហិង្សា ការបង្ក្រាបការបះបោរដោយប្រើកម្លាំង ឬសង្គ្រាម ឬសេចក្តីថ្លែងមានលក្ខណៈអុចអាលពូជសាសន៍។ មានមនុស្សជាច្រើនបានធ្វើការដោយមិនខ្លាចនឿយហត់ក្នុងជួររដ្ឋាភិបាលនិងខាងក្រៅរដ្ឋាភិបាល ដើម្បីធានាឲ្យមានការផ្លាស់ប្តូរដោយសន្តិវិធីនៅប្រទេសកម្ពុជា ពីជម្លោះ និងអំពើប្រល័យពូជសាសន៍ ទៅរកលទ្ធិប្រជាធិបតេយ្យ ស្របតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាសម័យទំនើប។ គន្លងនេះត្រូវតែបន្តទៅមុខទៀត។ វាជាអ្វីដែលប្រជាជនកម្ពុជាទាំងអស់សមនឹងទទួលបាន។

**ចប់**

*អ្នកស្រី សាស្ត្រាចារ្យ **រ៉ូណា ស្មីត** (ចក្រភពអង់គ្លេស) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងក្នុងខែមីនា ឆ្នាំ ២០១៥ ជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ ក្នុងនាមជាអ្នករាយការណ៍ពិសេស អ្នកស្រីគឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ដែលជាស្ថាប័នធំបំផុតមួយរបស់អ្នកជំនាញការឯករាជ្យ នៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឯករាជ្យ ឃ្លាំមើល និងស្វែងរកការពិត របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ អ្នកកាន់អណត្តិរបស់នីតិវិធីពិសេស ជាអ្នកជំនាញការសិទ្ធិមនុស្សឯករាជ្យ ដែលតែតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ដើម្បីដោះស្រាយទាំងស្ថានភាពជាក់លាក់នៃប្រទេសនីមួយៗ ទាំងបញ្ហាតាមវិស័យមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ពួកគេមិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ។ ពួកគេបម្រើការក្នុងសមត្ថភាពបុគ្គលរបស់ពួកគេផ្ទាល់ និងមិនទទួលប្រាក់បៀវត្សរ៍ពីការងាររបស់ខ្លួនឡើយ។*

*សូមឆែកមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីកម្ពុជា។*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ**សូមទាក់ទងមក លោក ម៉ាន់ សុវណ្ណា (Mr. Sovanna Mann) តាមរយៈទូរស័ព្ទលេខ (+៨៥៥ ២៣ ៩៩៣ ៥៩០/៩១ លេខភ្ជាប់បន្ត៖ Ext: ២០៨ ឬ អ៊ីម៉ែល smann@ohchr.org)*

សម្រាប់**ការសាកសួរព័ត៌មាន** អំពីអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖
លោក សាបៀរ សេឡាយ៉ា (Xabier Celaya) អង្គភាពប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន OHCHR តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ ឬ អ៊ីម៉ែល xcelaya@ohchr.org)

## អ្នកអាចរកបាននូវសេចក្តីប្រកាសព័ត៌មាននេះតាមអនឡាញបាន

តើលោក អ្នក ខ្វល់ខ្វាយអំពីពិភពលោកដែលយើងរស់នៅឬទេ? អញ្ចឹង យើង**ត្រូវក្រោកឈរដើម្បីសិទ្ធិនរណាម្នាក់នៅថ្ងៃនេះ** #Standup4humanrights និងចូលទៅកាន់ទំព័រវេបសាយ៖http://www.standup4humanrights.org